# ការសំភាសន៍របស់លោកតា រស់ អាង

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ រស់ អាង

## <u>ការសង្ខេបប្រវត្តិរបស់ លោកតា រស់ អាង</u>

លោកតា រស់ អាង មានអាយុ70ឆ្នាំ នៅក្នុងឆ្នាំ2018 លោកតា រស់ អាង មានភេទប្រុសលោកតា រស់ អាង មានទីលំនៅបច្ចុប្បន្ននៅ ភូមិទួល ឃុំមហាសាង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

កៈ ចឹងជាដំបូងខ្ញុំអរគុណតាដែរបានអោយខ្ញុំពិភាក្សាជាមួយតាដែរទាក់ទងពីប្រវត្តិរបស់តា ហើយការសំភាសន៍ទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយនឹង ប្រវត្តិរបស់ជូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍យាយ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយយាយ ចឹងដោយសារតែវេបសាយដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់តាយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ដែរបានពិភាក្សាជាមួយតាទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរទេតា?

ខៈ បាទមានអី

កៈ បាទតាបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍តាខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍តាគឺនៅថ្ងៃទី10ខែ4 ឆ្នាំ2018 ហើយឡើងនៅភូមិ?

ខៈ ភូមិទួល

កៈ ភូមិទួល ឃុំមហាសាង ស្រុក?

ខ៖  ស្រុកភ្នំស្រួច

ក៖  ស្រុកភ្នំស្រួច ខេត្តកណ្តាល អូខេត្តកំពង់ស្ពឺច្រឡំខេត្តកណ្តាល

ខ៖  ខេត្តកំពង់ស្ពឺ

ក៖  ខ្ញុំលឺតានិយាយខេត្តកណ្តាលនឹងខ្ញុំច្រឡំនៅខេត្តកណ្តាលដែរនឹង?

ខ៖  ខ្ញុំស្រុកកំណើតនឹងនៅខេត្តកណ្តាលណោះទេនឹង

ក៖  អ៎ូ!!ចឹងហោសតា?

ខ៖  ប៉ុន្តែខ្ញុំមកនៅនេះនឹងហាស យើងទៅនិយាយអីទៅណោះនឹងហាស

ក៖  បាទអត់ផងវាឈ្មោះបីម៉ា

ខ៖  បើនិយាយទៅវាវែងឆ្ងាយណាស់

ក៖  មិត្តភក្តិរបស់បងទេជាអ្នកផ្ញើរសារមកបងហោស?

ខ៖ បើនិយាយប្រវត្តិមកវាឆ្ងាយ

ក៖
អត់ទេចាំខ្ញុំសំភាសន៍តាហើយចាំខ្ញុំប្រាប់បងថាលេខទូរស័ព្ទនរណាគេនិយាយអីគេខ្លះដែរចឹងហាស ចឹងសំរាប់តាមានឈ្មោះពេញរបស់តានឹងមានឈ្មោះអីគេដែរតា?

ខ៖  មានឈ្មោះអាង

ក៖  ចុះមានឈ្មោះអីគេដែរអា ហោសតា?

ខ៖  មានឈ្មោះរស់ អាង

ក៖  ឈ្មោះរស់ អាង ចុះតាមានឈ្មោះហៅក្រៅទេតា?

ខ៖  អត់ទេ

ក៖  អត់មានទេណតា?

ខ៖  មានមកពីណាអត់មានផងនឹង

ក៖  ចុះតាកាលពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះតាអីផ្សេងដែរទេ?

ខ៖  អត់មានឈ្មោះអីផ្សេងទេនៅពីក្មេងនឹងក៏មានឈ្មោះតែប៉ុណ្ណឹង ហើយនៅហៅដដែលៗៗនឹងហាស

ក៖  ចឹងណតា ចុះតាសព្វថ្ងៃនឹងតាអាយុប៉ុន្មានដែរតា?

ខ៖  ខ្ញុំអាយុ70ឆ្នាំហើយនឹង

ក៖  ចឹងអាយុ70ឆ្នាំណាតា?

ខ៖  នឹងហើយអាយុ70ឆ្នាំ

ក៖  ចុះតាកើតនៅថ្ងៃខែឆ្នាំណាដែរតាមានចងចាំទេ?

ខ៖  អើរអត់ចងចាំទេចៅអើយ តាំងពីសម័យជំនាន់អ៊ីសារ៉ាក់ណោះខ្ញុំអត់ចាំទេ

ក៖  ចុះតាឆ្នាំវិញតាកើតនៅឆ្នាំអីគេដែរតា?

ខ៖  អត់ដឹងថាឆ្នាំណាដែរបើយើងមិនបានពិភាក្សាកន្លែងនឹងដែរ

ក៖  អូ៎!!តាកើតនៅឆ្នាំ1948តា?

ខ៖  នៅឆ្នាំ1948ចឹង

ក៖  ចុះតាឆ្នាំច័ន្ទគតិហាសតាឆ្នាំអីគេដែរទៅតា លក្ខណះឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖  ខ្ញុំកើតនៅឆ្នាំឆ្លូវ

ក៖  អូ៎!!តាកើតនៅឆ្នាំឆ្លូវហោសតា ចុះតាកើតនៅណាដែរតា?

ខ៖  អោយនិយាយពីប្រវត្តិនឹងខ្ញុំកើតនៅខេត្តកណ្តាលនឹង នៅស្រុកអង្គស្នួលហោស

ក៖  អូ៎!!ប៉ុន្តែភូមិអី ឃុំអីគេដែរតា?

ខ៖  នៅភូមិត្រពាំងទូល នៅស្រុកពើក

ក៖  នៅស្រុកពើក?

ខ៖  ស្រុកពើកនៅខេត្តកណ្តាលនឹង

ក៖  ឃុំអីគេដែរតា?

ខ៖  ឃុំអង្គស្នួល

ក៖  ឃុំអង្គស្នួល ចុះភូមិវិញតា?

ខ៖  ភូមិ ត្រពាំងទួល

ក៖  ភូមិត្រពាំងទួល?

ខ៖  ភូមិត្រពាំងទួល

ក៖  ចុះតាមានបងប្អូនចំនួនប៉ុន្មាននាក់ដែរតា?

ខ៖  មកសព្វថ្ងៃនឹងមានប៉ុន្មាន4នាក់នឹងហាស

ក៖  ចឹងមានបងប្អូនចំនួន4នាក់ណាតា?

ខ៖  មានបងប្អូនរស់ប៉ុន្មាន នឹងស្លាប់ប៉ុន្មានប្រាប់គាត់ទាំងអស់ទៅ ចុះស្លាប់ណាគេនិយាយដែរអត់ចងចាំផងនឹង

ក៖  អត់ទេតាមានចងចាំថាបងប្អូនរបស់តាទាំងអស់តែម្តងនឹងមានប៉ុន្មាននាក់ដែរតា?

ខ៖  ហេ៎!!ច្រើនដែរនឹងហាស ប៉ុន្តែមានស្លាប់អស់ខ្លះដែរនឹងជំនាន់ណុង

ក៖  ប៉ុន្តែតាអត់មានចងចាំទេណាតា?

ខ៖  ខ្ញុំអត់មានចងចាំទេ

ក៖  ប៉ុន្តែអ្នកដែរនៅរស់នឹង?

ខ៖  គ្រាន់តែបងប្អូនសោះនឹងក៏អត់ចាំដែរ បើចាំនឹងស្លាប់នឹងស្លាប់3នាក់ ហើយនៅរស់នឹងនៅសល់4នាក់

ក៖  ចឹងហោសតាបាទ?

ខ៖  នៅទាំងខ្ញុំអីនឹងវាមាន4នាក់នឹង

ក៖  ប៉ុន្តែតាជាកូនទីប៉ុន្មានដែរតា?

ខ៖ មើលជាកូនទី3នឹង

ក៖ ចុះតាបងប្អូនមានស្រីប៉ុន្មាននាក់ ហើយនឹងប្រុសប៉ុន្មាននាក់ដែរតា?

ខ៖ មានស្រី2នាក់នឹងប្រុសមើល

ក៖ មានប្រុស5នាក់?

ខ៖ នឹងហើយមានប្រុស5នាក់នឹងហើយ

ក៖ ចុះតាមានចងចាំឈ្មោះទាំងអស់នឹង រឺតាចាំឈ្មោះដែរអាចរៀបរាប់បានចឹងហាស?

ខ៖ ចាំនៅឈ្មោះស្លាប់អីនឹងពិបាកដែរនឹង

ក៖ ប៉ុន្តែអ្នកដែរនៅរស់នឹងក៏បានដែរតា?

ខ៖ នៅរស់ហោស?

ក៖ បាទតាបាទនឹង?

ខ៖ នៅរស់នឹងមានឈ្មោះសុខ ខុន ហើយនឹងមានឈ្មោះពៅ ទូចៗ

ក៖ ហើយនឹងមានឈ្មោះពៅ ទូចៗៗ?

ខ៖ មីងពៅគេនោះហៅពៅៗៗហើយនឹងឈ្មោះវានឹងឈ្មោះទូច

ក៖ ឈ្មោះពៅៗៗ ទូចៗៗខ្ញុំស្តាប់អត់បាន?

ខ៖ មានឈ្មោះទូចនឹងហើយ ខ្វិលហៅពៅអីនឹង

ក៖ បាទតាបាទ?

ខ៖ ចឹងបានជាមិនចង់អោយសំភាសន៍នឹងហើយ

ក៖ អត់ទេអីទេតាដោយសារតែ?

ខ៖ អត់អីទេប្រាប់មកចាំខ្ញុំជួយបកប្រែ

ក៖ ចុះតាកាលពីក្មេងនឹងតាធ្លាប់លេងអីជាមួយបងប្អូនតាដែរទេ?

ខ៖ ហ៉ើ!!ធ្លាប់តែលេងបាយឡឹកបាយឡនឹងហាស

កៈ ចុះធ្លាប់លេងបិទពួន រឺធ្លាប់ទៅស្រែអីជាមួយគ្នាដែរទេតា?

ខៈ មានលេងដែរបិទពួនចឹងទៅ លេងលោតអន្ទាក់ចឹងទៅ

កៈ អូ៎!!បាទតាបាទ
ចុះតាចូលចិត្តលេងអីគេជាមួយបងប្អូនរបស់តាដែរកាលពីនៅក្មេងហាស?

ខៈ មានតែលេងបាយឡឹកបាយឡទេកាលនៅក្មេងនឹង

កៈ អូ៎!!ចឹងហោសតា?

ខៈ យើងដាំស្លចឹងទៅនៅក្មេងតូចៗៗណាស់ជំនាន់ណុង

កៈ អូ៎!!បាទតាបាទ?

ខៈ មានតែលេងចឹង

កៈ បាទ!ចុះតាគិតថាបងប្អូនរបស់តានឹងសព្វថ្ងៃនឹងគាត់នៅណាដែរតា?

ខៈ នៅឪវ៉ាល់នឹងមួយ នៅទំនុបទឹកនោះមួយ នៅទំនុបទឹកត្រពាំងក្រលឹងហោស

កៈ បាទតាចឹង?

ខៈ មានប៉ុណ្ណឹងនៅបែកគ្នាចឹងហាសមួយនៅម៉ុងពោសាត់ហោស

កៈ អូ៎!!នៅឆ្ងាយណាតា?

ខៈ នៅឆ្ងាយចឹងបានខ្ញុំមិនចង់ នៅបែកគ្នាឆ្ងាយៗៗចឹងហាស

កៈ ចុះពួកគាត់ធ្វើអីគេខ្លះដែរតា?

ខៈ បាទថាម៉េច?

កៈ ពួកគាត់អីសំរាប់ចិញ្ចឹមជីវិតដែរតា?

ខៈ ឪពុករបស់ខ្ញុំហោស?

កៈ អត់ទេបងប្អូនរបស់តាហាសគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតហាសតា?

ខ៖ មានធ្វើអង្គការខ្លះទៅធ្វើសេរី ហេខាងនេះហេភ្លេចទៅណាស់ គេហៅអង្គការអិលហោស

ក៖ អ៊ូ!!អង្គការអិលហោសខ្ញុំអត់ស្គាល់ដែរនឹង?

ខ៖ អង្គការអិលនឹងនៅខាងព្រៃឈើ

ក៖ អ៊ូ!!ចឹងហោសតា ចុះឪពុករបស់តានឹងមានឈ្មោះអីគេដែរតា?

ខ៖ ឪពុករបស់ខ្ញុំមានឈ្មោះរស់ គង់

ក៖ ប៉ុន្តែដូចជា?

ខ៖ ឪពុកខ្ញុំឈ្មោះគង់ ហើយឪពុកគាត់មានឈ្មោះរស់

ក៖ បាទតាចុះសំរាប់យាយមានឈ្មោះអីគេដែរទៅតា?

ខ៖ យាយហោសយាយ?

ក៖ ម្ដាយរបស់តាហាស?

ខ៖ ម្ដាយរបស់ខ្ញុំនឹងមានឈ្មោះនេសាង

ក៖ ចុះឪពុករបស់តាគាត់កើតនៅណាដែរតាដឹងទេ?

ខ៖ គាត់កើតនៅនឹងទាំងអស់នឹង

ក៖ ចុះយាយក៏នៅនឹងដែរ?

ខ៖ បាទ!!នៅនឹងដែរនឹង

ក៖ អ៊ូ!!បាទតា ចុះឪពុករបស់តានឹងគាត់នៅរស់រឺមួយក៏គាត់ស្លាប់ហើយនឹងតា រឺមួយក៏គាត់នៅរស់ទេ?

ខ៖ គាត់មកនឹងគាត់ស្លាប់មុខរដ្ឋប្រហារ

ក៖ អ៊ូ!!ចឹងហោសតាណា?

ខ៖ នឹងហើយវាចឹង

កៈ ចុះសំរាប់ឪពុករបស់តាកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរតា?

ខៈ អ៎ូ!!ឪពុករបស់ខ្ញុំនឹងកំសត់កំរណាស់ ជាជាងកាត់សក់ផង
ធ្វើត្បាល់កិនផងធ្វើនុំបញ្ចុះផងនឹង

កៈ អ៎ូ!!បាទតាបាទ?

ខៈ ធ្វើគ្រប់មុខនឹង

កៈ បាទតាបាទ?

ខៈ កំសត់កំរចឹងបានជាខ្ញុំអត់ចង់សំភាសន៍អីនឹងហាស

កៈ អត់អីទេតាអ្វីដែរតា?

ខៈ ជាជាងកាត់សក់ផងនឹង

កៈ តានិយាយអ្វីដែរតាចងចាំផងទៅនឹង?

ខៈ បាទនឹងហើយ

កៈ ចុះសំរាប់ឪពុករបស់តានឹងគាត់ស្លូតរឺមួយក៏កាចដែរតា?

ខៈ ឪពុករបស់ខ្ញុំនឹងគាត់ស្លូតអត់មានកាចទេនឹង គាត់ក៏មិនសូវចេះហូ
បអីដែរគាត់ហូបពេលបាយចឹងណាស់
ចឹងគាត់ប្រើខ្ញុំទៅទិញមួយកែវចឹងទៅស្រាសពីដើមហាស
ទិញមានមួយកាក់ពីរកាក់ចឹងទៅ

កៈ បាទតាបាទ ចុះតាគិតថាម្តាយរបស់តាគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរតា?

ខៈ គាត់ធ្វើនុំបញ្ចុះចឹងទៅ ស៊ីឈ្នួលគេដើរស្ទូងដកចឹងទៅ

កៈ ចុះម្តាយរបស់តាវិញដូចជាគាត់កាចរឺមួយក៏គាត់ស្លូតដែរតា?

ខៈ គាត់អត់អីដែរនឹងគាត់កាចក៏មិនកាច ស្លូតក៏មិនស្លូតគាត់ល្មម

កៈ ចឹងគាត់ធម្មតាទេណតា
ចុះម្តាយរបស់តានឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទៅតាដែរទេ?

ខ៖ អត់ទេ

ក៖ អត់ដែរទេនតា?

ខ៖ អត់ដែរទេ

ក៖ ចុះឪពុករបស់តានឹងក៏អត់ដែលនឹង?

ខ៖ អត់ដែរនឹង

ក៖ ចុះតាមានចងចាំអនុស្សាវរីយ៍អីគេមួយឪពុកម្ដាយរបស់តាដែរ តាគិតថាតាចងចាំអត់ភ្លេចដែរទេជាមួយពួកគាត់ហាស?

ខ៖ មានតែ

ក៖ ធ្វើស្រែចំការអី?

ខ៖ មានតែធ្វើស្រែចំការតែប៉ុណ្ណឹងឯងនឹង នឹងធ្វើត្បាល់កិន នឹងធ្វើកាត់សក់នឹងអត់មានភ្លេចទេ

ក៖ អូ៎!ចឹងហោសតា?

ខ៖ ហើយយើងពីជំនាន់នឹងកិនធ្វើជាកម្មករគេណាកិនស្រូវចឹងទៅកិនម៉ាស៊ីន

ក៖ ចឹងហោសតា ចុះ?

ខ៖ ធ្វើនៅរោងម៉ាស៊ីនចឹងទៅ

ក៖ ចុះយាយតាខាងឪពុកនឹងតាមានស្គាល់ឈ្មោះគាត់ដែរទេ យាយតាខាងឪពុកតាទៀតហាស?

ខ៖ ថីមិនស្គាល់តារស់

ក៖ ចុះយាយវិញ?

ខ៖ មានឈ្មោះយាយសរ

ក៖ ចុះយាយតាខាងម្ដាយវិញតា?

ខ៖ មានឈ្មោះតាសួន យាយអ៊ីវ

កៈ  អូ៎!!បាទ ចុះតាមានដឹងថាយាយតាខាងឪពុកនឹងគាត់កើតនៅណាដែរទេ?

ខៈ  កើតនៅនឹងដែរកើតទាំងអស់នឹងទាំងអស់នឹង

កៈ  ទាំងខាងម្ដាយក៏នៅនឹងដែរណតា?

ខៈ  ទាំងអស់នឹងហាស

កៈ  អូ៎!!បាទតានឹងហើយ?

ខៈ  កើតនៅជាមួយគ្នាទាំងអស់នឹង

កៈ  ចុះដូចជាតាមកនៅនឹងយូរនៅតា?

ខៈ  តាំងពីសម័យអ៊ីសារ៉ាក់ណោះ

ក  អូ៎!!ចឹងមានន័យថាប្រហែលជាចូល60-70ឆ្នាំហើយណតា?

ខៈ  បាទនឹងហើយ តាំងពីសម័យនឹងមករហូតដល់សព្វថ្ងៃនឹងថាតិចហី

កៈ  បាទចុះតាមានបងប្អូនជីដូនមួយ រឺមានបងប្អូនកូនចៅណាដែរទៅរស់នៅក្រៅប្រទេសក្រៅពីស្រុកខ្មែរដែរទេតា?

ខៈ  អើរអត់ដែរនឹងហាស

កៈ  អូ៎!!អត់មានទេហោស ទៅថៃ ទៅវៀតណាមអីនឹងអត់មានទេហោសតា?

ខៈ  អត់មានទេ

កៈ  ចុះសំរាប់ភរិយារបស់តានឹងមានឈ្មោះអីគេដែរតា?

ខៈ  មានឈ្មោះតេង សឿនភរិយារបស់ខ្ញុំត្រូវជាប្អូនគាត់

កៈ  អូ៎!!បាទ
ចុះសំរាប់ដូចជាតាមានចងចាំថាតារៀបអាពាហ៍ពិពាហ៍ជាមួយភរិយាជាមួយតានឹងនៅឆ្នាំណាដែរទេ?

ខៈ រៀបនៅឆ្នាំ1972នឹង

កៈ  អូ៎!!នៅឆ្នាំ1972ហោសតា?

ខ៖ នៅឆ្នាំរដ្ឋប្រហារនឹងនៅលុនណុលនឹង

ក៖ ចុះតាពីជំនាន់ណុងតាមានជាអីជូនទៅយាយដែរទេ?

ខ៖ អត់មានអីផងនឹងអត់មានកាដូអីទេ

ក៖ អូ៎!!ចឹងហោសតា?

ខ៖ អត់មានជាកាដូអីទេជំនាន់លុនណុលហើយជំនាន់ខ្មែរក្រហមពេញហើយនឹង

ក៖ អូ៎!!បាទតាបាទ?

ខ៖ កើតនៅខ្មែរក្រហមហើយនឹង

ក៖ ចុះតានៅពេលដែរតារៀបអាពាហ៍ពិពាហ៍នឹងគិតថាចិត្តចង់រៀបដោយខ្លួនឯងរឺមួយក៏ឪពុកម្ដាយអ្នករៀបចំអោយ?

ខ៖ ម្ដាយទេឪពុកស្លាប់បាត់ហើយ

ក៖ អូ៎!!ចឹងហោស?

ខ៖ ម្ដាយទេគាត់ជាអ្នកចូលស្ដីអោយនឹង
កាលពីពេលការនឹងក៏អត់មានភ្លេងអត់មានមេក្រូអីដែរ ស្វាត់ជ្រាបគដីនឹងហាស

ក៖ ចឹងហោសតា?

ខ៖ ចុះខ្មែរក្រហមនឹងនៅពាស់នឹងហើយនឹង

ក៖ បាទតា ចុះដូចជានៅពេលដែរតារៀបអាពាហ៍ពិពាហ៍ជាមួយយាយនឹងដូចជាតាស្គាល់យាយនៅពេលណា ស្គាល់បានប៉ុន្មានឆ្នាំហើយ
រយះពេលប៉ុន្មានតាចូលស្ដីដណ្ដឹងយាយចឹងហាស?

ខ៖ រឿងមួយឆ្នាំនឹងអត់ទេ តិចខែដែរនឹងពីរបីខែនឹង

ក៖ អូ៎!!ពីរបីខែណាតា?

ខ៖ បាទនឹងហើយ

ក៖ ចុះតាធ្លាប់បានរៀនទេតា?

ខ៖ ខ្ញុំអត់បានរៀនអត់បានអីទេ មើលចឹងបានកំសត់នឹង
មើលតែប្អូនហើយនឹងមើលបំពេនឹង

ក៖ អ៊ូ!!បាទតាបាទ?

ខ៖ បងគេហើយប្អូនៗៗនឹងសុទ្ធតែចេះ អត់តែខ្ញុំមួយនឹង

ក៖ ចុះតាមានចេះភាសាអីក្រៅពីភាសាបារាំងអីទេ?

ខ៖ អត់មានទេ

ក៖ ថៃ វៀតណាមអីអត់ចេះដែរហោស?

ខ៖ អត់ចេះទេ

ក៖ ចុះតាមានមិត្តភក្តិដែរធំធាត់មកជាមួយគ្នាដែរទេតា?

ខ៖ បាទ!ថាម៉េច?

ក៖ ធ្លាប់មានមិត្តភក្តិដែរធំធាត់មកជាមួយគ្នាអត់?

ខ៖ ធំធាត់ហី?

ក៖ កាលពីតូចៗៗនឹងហាសធ្លាប់មានដែរទេ?

ខ៖ អ៊ូ!!វាបែកឆ្ងាយអស់ហើយនឹង មិនដឹងនៅណាៗទៅណាអស់ហើយនឹង
វាចេះតែមានហើយប៉ុន្តែ ទៅឆ្ងាយៗៗអស់ហើយនឹងដឹងគេទៅនៅណា

ក៖ អ៊ូ!!បាទតាបាទ?

ខ៖ ពីមុនមកនឹងចេះតែមានហើយចឹងទៅ ពួកម៉ាក់ចឹងទៅ

ក៖ ចុះសំរាប់តាគិតថាមិត្តភក្តិរបស់តានឹងតាមានចងចាំឈ្មោះទេ?

ខ៖ អត់ទេ

ក៖ អ៊ូ!!ចុះ តាមានធ្លាប់នឹកចាំថាអនុស្សាវរីយ៍ជាមួយមិត្តភក្តិតាហាស?

ខ៖ គាត់មិនសូវជាចងចាំទេជំនាន់ណុងបែកគ្នានៅសង្គមលុនណុលចូលខ្មែរក្រហមនឹង

កៈ  អត់អីទេបងឯងទៅចុះលែងរកបងឯងហើយ
ចុះសំរាប់តាតាំងពីក្មេងរហូតមកដល់ពេលនេះហាស តាមានធ្លាប់បានធ្វើអីគេខ្លះដែរតា?

ខៈ  ខ្ញុំហោសពីក្មេងមកនឹងមានតែអ្នកឡើងត្នោតហើយនឹង
ធ្វើរោងម៉ាស៊ីនហើយដឹកទឹកចឹងទៅ ដឹកទឹកលក់ចឹងទៅ

កៈ  អូ៎!!បាទតា ចុះតាគិតថាតាធ្លាប់ទៅធ្វើស្រែចំការដែរទេ?

ខៈ  បាទធ្លាប់

កៈ  ប៉ុន្តែតាធ្វើអីគេខ្លះដែរនៅណុង?

ខៈ  ធ្វើស្រែផង ធ្វើចំការផងនឹងជួនណាដាំឆៃថាវចឹងទៅ

កៈ  អូ៎!!ចឹងហោសតា?

ខៈ  ជួនណាដាំស្ពៃចឹងទៅ

កៈ  ចុះតាគិតថាតាធ្លាប់បង្កើតអាជីវកម្មលក់ដូរអីទេតា?

ខៈ  អត់ទេបើថាដាំយកលក់ដាំយកទៅលក់នៅផ្សារចឹងទៅដាំ

កៈ  បាទតាបាទ?

ខៈ  បើសិនជាអោយមានអីនឹងអត់?

កៈ  បាទតាបាទ!! ចុះសំរាប់តាគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាស
ជីវិតរបស់តានឹងមានការផ្លាស់ប្តូរអីផ្សេងដែរទេតា?

ខៈ  អត់ទេមានតែប៉ុណ្ណឹងនៅក្នុងជីវិតនឹង

កៈ  អូ៎!!ចឹងណាតា?

ខៈ  មានតែធម្មតានឹង

កៈ  ចុះម្ហូបដែរតាចូលចិត្តពិសារដែរតា?

ខៈ  អូ៎!!ខ្ញុំរឿងម្ហូបដែរចូលចិត្តពិសារនឹងមានតែរបស់ក្រៀមក្រស់នឹង

កៈ  ចុះការី កកូរ ឆា ចៀន ស្ងោរអីនឹងតាចូលចិត្តដែរទេ?

ខ៖ ចូលចិត្តបានតែម្តងៗៗទេតែបើឡើងដល់ទៅពីរបីដងនឹងគឺទៅអត់រួចទេ

ក៖ ចឹងតាចូលចិត្តតែក្រៀមក្រស់ទេណាតា?

ខ៖ បាទ!!ស្លម្ជូរចឹងទៅ ម្ជូរស្លឹកថ្នឹងចឹងទៅ ម្ជូរស្លឹកតាងៀងចឹងទៅ
អានឹងក្រៀមក្រស់ហើយនឹង

ក៖ បាទតាបាទនឹង ចុះសំរាប់ល្បែងប្រជាប្រិយ៍អីដែរតាចូលចិត្តលេងពីក្មេងហាស?

ខ៖ ល្បែងប្រជាប្រិយ៍ហី?

ក៖ បាទតាបាទនឹង?

ខ៖ មានតែចង់រាំវង្សតែម្តងនឹងមានតែប៉ុណ្ណឹង នឹងមានតែប៉ុណ្ណឹង

ក៖ ប៉ុន្តែដូចជាចោលឈូង ទាញព្រាត លាក់កន្សែង?

ខ៖ នឹងហើយចង់ទាំងអស់នឹងហាស

ក៖ អូ៎!!ប៉ុន្តែកាលពីក្មេងៗៗនឹងតាលេងទាំងអស់ដែរណាតា?

ខ៖ លេងពងក្អែកអីចឹងទៅ

ក៖ លេងអីគេដែរតា លេងធាក់ពងក្អែក?

ខ៖ លេងធាក់ចឹងទៅពេលធាក់ត្រូវចឹងទៅវាស្អុយហើយនឹង
ស្រីៗៗធាក់ចឹងស្អុយហើយនឹង យើងឈរមួយកន្លែងចឹងទៅ ធាក់ពងក្អែក
នឹងទាញឈូងចឹងទៅ

ក៖ មិនមែនលេងដូចយាយទេលេងស្វាដណ្តើមគ្នាណាហីតា?

ខ៖ ចាទ!!អានឹងម៉្យាងដែរ យើងអូសឈូងចឹងទៅ

ក៖ បាទតាបាទ ចុះតាគិតថាចេះច្រៀងអត់តា?

ខ៖ បាទខ្ញុំអត់ចេះទេនឹង

ក៖ ចុះតាចូលចិត្តស្តាប់បទចំរៀងអត់តា?

ខ៖ ចង់បើនិយាយចឹងចង់តែម្តងនឹងចង់អត់មានភ្លេងការក៏ចង់ដែរ បទចំរៀងខ្មែរនឹងក៏ចង់ដែរ

ក៖ ប៉ុន្តែលក្ខណៈបទបុរាណ រឺមួយបទសម័យដែរតាចង់នឹង?

ខ៖ បទសម័យទាំងអស់នឹង

ក៖ ចឹងហោសតាណា?

ខ៖ បាទ!!បទបុរាណទាំងអស់នឹង ហើយក្រៅពីនឹងបទអីក៏អត់ចេះដែរ

ក៖ អូ!!ចុះតាគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសាររបស់តានឹងចេះលេងឧបករណ៍ភ្លេងដែរទេតា បងប្អូនជីដូនមួយក៏ដោយ?

ខ៖ អូ!!ឪពុករបស់ខ្ញុំនឹងគាត់ចេះភ្លេងដែរនឹងភ្លេងការ

ក៖ អូ!!ចឹងហោសតា?

ខ៖ ប៉ុន្តែខ្ញុំរៀនអត់ចេះទេ

ក៖ ប៉ុន្តែតាចង់ដែរហោសតា?

ខ៖ ចង់ប៉ុន្តែវាមិនចេះទ្រមានអីមានកូដអត់ចេះតែម្តងនឹង

ក៖ អូ!!ឪពុករបស់តានឹងគាត់លេងអីគេដែរ?

ខ៖ គាត់លេងភ្លេងការ

ក៖ អូ!!ភ្លេងការណាតា?

ខ៖ គាត់មកគាត់ដើរកាត់សក់ផង បោះត្បាល់កិនផងនឹង ធ្វើនុំបញ្ចុះលក់ផងនឹង

ក៖ បាទតាបាទ ចុះតាគិតថា?

ខ៖ ភ្លេងការផងនឹង

ក៖ តាគិតថាផ្ទះរបស់តាមានលក្ខណៈបែបណាតាំងពីក្មេងរហូតមកដល់ពេលនេះហាសតា?

ខ៖ តាំងពីក្មេងនឹងមានតែប៉ុណ្ណឹងនោះនៅខាងលិចនឹងហាស

ក៖ អូ៎!!បាទតាបាទ?

ខ៖ ផ្ទះនៅខាងលិចនឹង

ក៖ ចុះសំរាប់តាគិតថាផ្ទះរបស់តា?

ខ៖ អត់បានផ្ទះខ្ពស់នឹងគេទេបានផ្ទះតៀម

ក៖ ចុះតាគិតថានរណាគេជាអ្នកសាងសងដែរតា?

ខ៖ បាទខ្ញុំនឹងតែម្តងនឹង

ក៖ អូ៎!!តាចេះធ្វើផ្ទះហោសតា?

ខ៖ អូ៎!!ជួលគេតែម្តងនឹង យើងជាអ្នកដាក់

ក៖ យើងជាអ្នកចេញលុយចេញអីធ្វើណាតា?

ខ៖ បាទ!!នឹងជាអ្នកចេញធ្វើនឹងហាស

ក៖ អូ៎!!បាទតា ចុះតាគិតថាជំនាញអីដែរតាចេះស្ទាត់ជំនាញដែរតា?

ខ៖ អត់មានជំនាញអីក្រៅពីធ្វើស្រែទេខ្ញុំ

ក៖ អូ៎!!តាជំនាញធ្វើស្រែណាតា?

ខ៖ ជំនាញធ្វើស្រែនឹងតែម្តងនឹង

ក៖ ដក ស្ទូងចឹងទៅ?

ខ៖ ដក ស្ទូងចឹងតែម្តងនឹងមានតែប៉ុណ្ណឹងទេនឹង
អស់ហើយនឹងជំនាញខ្ញុំអត់កើតតែម្តងនឹងចោលស្រែអត់កើតនឹង

ក៖ អូ៎!!បាទតាបាទ?

ខ៖ បាទនឹងហើយចឹង

ក៖ ចុះតាគិតថាឪពុកម្តាយរបស់តានឹងធ្លាប់បង្រៀនពីជំនាញអីមួយទៅតាដែរទេ?

ខ៖  គាត់អត់ដែរបានបង្រៀនខ្ញុំដែរនឹងប៉ុន្តែខ្ញុំអត់ចេះតែម្តងនឹង ដូចខ្ញុំថាចឹងរៀនទ្រនឹងខ្ញុំអត់ចេះនឹងគេទេ កាត់សក់ក៏អត់ដែរក៏អត់ចេះដែរ

ក៖  បាទតា ចុះតាគិតថាជំនាញអីដែរដែរតាចេះដូចជា ជំនាញវេញវល្លិ៍ កូរស្ករត្នោត ធ្វើផ្តៅ ធ្វើកន្ទេលធ្វើអីនឹងតាចេះទេ?

ខ៖  ខ្ញុំស្ករត្នោតនឹងខ្ញុំចេះ នឹងឡើងត្នោតនឹង

ក៖  អូ៎!!តាចេះឡើងត្នោត នឹងកូនស្កត្នោតហោសតា?

ខ៖  បាទនឹងចេះ

ក៖  ចុះតាអាចប្រាប់ពីកាលលំបាកបានទេ នៅក្នុងជីវិតរបស់តាថាតាមានការលំបាកអីគេខ្លះដែរ?

ខ៖  អូ៎!!លំបាកណាស់ចៅអើយ

ក៖  តាំងពីក្មេងហាស?

ខ៖  ពីក្មេងនឹងលំបាកដែរចៅអើយលំបាករហូតនឹង នឹងចិញ្ចឹមបងចិញ្ចឹមប្អូននឹង មានតែខ្ញុំទេចិញ្ចឹមប្អូន រហូតទាល់តែទៅនៅជាមួយគេក៏ដែល ធ្វើការអីក៏ដែរនឹង

ក៖  បាទតាចុះកាលពីជំនាន់លុនណុលនឹងតា គិតថាមានការលំបាកអីគេដែរទៅតា?

ខ៖  លំបាកមែនទែនជំនាន់លុនណុលខាងធ្វើជាទាហ៊ាននឹងតែម្តងនឹងលំបាកហាស

ក៖  អូ៎!!តាធ្វើជាទាហ៊ានហោសតា?

ខ៖  បាទនឹងហើយ សុទ្ធតែមានគ្រាប់អស់ហើយចៅអើយ ដូចទឹកភ្លៀងចឹង

ក៖  គ្រាប់ហោសតា?

ខ៖  គ្រាប់ភីវ១ៗចឹង ច្រាស់ៗៗហាសណាស់

ក៖  អូ៎!!ចឹងហោសតា?

ខ៖  ល្មមបានអាយុប៉ុណ្ណឹងនឹង បានអាយុប៉ុណ្ណឹងសំណាងហើយនឹងដូចឆ្អឹងចឹងហាស

ក៖  បាទតាបាទ?

ខ៖ ចុះទឹកភ្លៀងចឹងគេថាទឹកភ្លៀងចឹងគេថាទឹកភ្លៀងយ៉ាងម៉េចចឹងហើយនឹង

ក៖ បាទតាបាទនឹង?

ខ៖ មិនមែនដូចឥឡូវនឹងយើងស្ទាត់ចេះទេនឹង

ក៖ ចុះតាគិតថាកាលពីជំនាន់ពលពតនឹងតាគិតថាតាមានការលំបាកអីផ្សេងទៀតតា?

ខ៖ ជំនាន់ពលពតហោស?

ក៖ បាទតាបាទ?

ខ៖ ពលពតនឹងពិបាកមួយចប់នឹង
យើងចេះជាងគេចឹងទៅគេអោយភ្ជួរចឹងទៅគេចអោយធ្វើទីចឹងទៅ ហោសគេអោយទៅដក
ទៅអានេះទៀតទៅនឹង យ៉ាប់ហាស

ក៖ គេអោយទៅណាចឹងយើងទៅណុងហើយណតា?

ខ៖ បាទៗនឹងហើយស្រេចតែគេបញ្ជានឹង

ក៖ ប៉ុន្តែពេលណុងដូចជាគេជំលាសតាទៅណាដែរតា?

ខ៖ នេះជំលាសជិតទេ ជំលាសទៅអីនេះដល់ហើយបានគេបញ្ចុះមកវិញ

ក៖ បាទតាបាទ?

ខ៖ គេអោយទៅលិច

ក៖ អូ!!បាទតាបាទចុះ?

ខ៖ ដល់នេះហើយនឹងបានចុះមកលិចវិញនឹង

ក៖ អូ!!ប៉ុន្តែដូចជាគេអោយតាធ្វើអីគេដែរទៅតា?

ខ៖ បាទថាម៉េច?

ក៖ គេអោយតាធ្វើអីគេដែរទៅតា?

ខ៖ ដល់ពេលដែរចុះមកវិញនឹងគេអោយធ្វើស្រែធ្វើអីនឹង ខ្ញុំវាចេះតែប៉ុណ្ណឹង
មកដល់គេអោយបញ្ជាអោយ ធ្វើស្រែព្រុះថ្នាលចឹងទៅ ព្រុះសំណាបចឹងទៅ

កៈ អូ៎!!បាទតាបាទ?

ខៈ បាទគេមិនអោយធ្វើអីទេនឹងគេអោយធ្វើតែ ធ្វើស្រែនឹងហាស ដើរដល់ពាក់កណ្ដាលចឹងទៅបានគេ អោយដើរជីកប្រឡាយដើរកាប់ព្រៃចំការដាំពោត ដាំបន្លែអីចឹងទៅណាស់

កៈ អូ៎!!ចេះតែធ្វើទៅណតា?

ខៈ ចេះតែធ្វើចឹងទៅ ចុះគេអោយទៅណាចឹងទៅនឹងហើយ

កៈ ចុះរបបអាហារនឹងយ៉ាងម៉េចដែរតា?

ខៈ បាទថាម៉េច?

កៈ របបអាហារនឹង?

ខៈ អើយរបបអាហារបើនិយាយទៅនឹងជួចត់សំបើមណាស់

កៈ អូ៎!!ប៉ុន្តែគេមានជំលាសតាទៅខេត្តអីផ្សេងទៀតទេតា?

ខៈ បាទ!!អត់មានទេនៅតែខេត្តយើងនឹងប៉ុន្តែដើរ

កៈ អូ៎!!បាទតាចឹងហោសតា?

ខៈ មាន4នាក់មួយកំប៉ុងៗៗនឹង

កៈ ប៉ុន្តែទៅជាគ្រួសាររឺមួយក៏ទៅជាផ្សេងដែរតា លក្ខណះថាគេជំលាសនឹងទៅជាគ្រួសារ រឺមួយគេជំលាសតាទៅម្នាក់ឯងដែរតា?

ខៈ ជួនណាបែកគ្រួសារចឹងដែរណា គេអោយដើរតាមកងចឹងទៅ

កៈ បាទតាបាទ?

ខៈ គ្រួសារទៅផ្សេងចឹងទៅ

កៈ បាទតាបាទនឹង?

ខៈ ខ្ញុំទៅកន្លែងផ្សេងដែរចឹទៅពេលណាបានជួបគ្នាចឹងទៅ

កៈ បាទតាបាទ?

ខ៖ បានតែកន្លះខែចឹងទៅបានបែកគ្នាចឹងទៅកំសត់ណាស់ចៅអើយ

ក៖ ចុះបងប្អូនរបស់តានឹងគេអោយធ្វើអីដែរតា?

ខ៖ អត់មានអោយធ្វើអីទេអោយធ្វើតែស្រែនឹងហាស

ក៖ អូ៎!!ចឹងហោសតាបាទតាបាទ?

ខ៖ កាប់ចំការអីចឹងទៅណាស់

ក៖ អូ៎!!បាទតា ចុះតាគិតថានៅពេលដែរដាច់ពលពតហាស
ពេលណុងពួកវៀតណាមចូលមកលក្ខណះថាចាប់ធ្វើជាទាហ៊ានហីតា?

ខ៖ បាទៗ!!នឹងហើយចឹង

ក៖ ចុះពេលណុងតាគេមានបានធ្វើអត់តា?

ខ៖ អត់ទេខ្ញុំអត់ទេខ្ញុំ គេអត់មានចាប់ទេគេអោយធ្វើស្រែនឹងរហូតនឹង

ក៖ ចុះបងប្អូនរបស់តា?

ខ៖ បងប្អូនក៏នៅចឹង

ក៖ អត់មាននរណាគេទៅធ្វើជាទាហ៊ានទេណាតា?

ខ៖ បាទអត់មានទេ
ហើយដល់នេះមកនឹងបានគេជ្រើសរើសស័គ្រចិត្តចឹងទៅគេទៅខ្លួនគេចឹងទៅ
ធ្វើជាទាហ៊ានចឹងទៅ

ក៖ បាទតាបាទ ចុះតាគិតថាឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរតា?

ខ៖ ហើយយ៉ាប់ណាស់ចៅអើយរកនិយាយអត់ត្រូវទេ

ក៖ អូ៎!!បាទតាចឹងហោសតា?

ខ៖ ពីដំណាក់កាលមួយទៅដំណាក់កាលមួយនឹងពិបាករហូតនឹង

ក៖ បាទតា
ចុះតាគិតថាពេលដែរតាគិតថាជាពេលដែរសប្បាយនៅជីវិតរបស់តាដែរទៅតា?

ខ៖ បានមកឥឡូវនឹងទេគ្រាន់បានសប្បាយ
គ្រាន់ថាដើរហើរអីបានអាចដើរបានតាមចិត្តទូលាយ
ដូចពីមុនឹងអត់មានទេរកដើរមិនកើតទេពលពតនោះ

ក៖ បាទតាបាទ
ចុះតាគិតថាពីក្មេងតាមានគោលបំណងថាពេលដែរតាធំឡើងនឹងតាចង់ធ្វើអីគេដែរទេ?

ខ៖ ចេះតែចង់ហើយប៉ុន្តែជំរើសខ្លួនឯងនឹងអត់ចេះទេ

ក៖ តែតា?

ខ៖ ចង់ធ្វើពេទ្យក៏ចង់ប៉ុន្តែ

ក៖ ទៅអត់ដល់ណតា?

ខ៖ ប៉ុន្តែអត់ចេះទេទៅអត់រួចនឹងហាស

ក៖ អូ!ចឹងណតា?

ខ៖ ជំនាន់លុនណុលនឹងបើចេះពេទ្យវិញហូចូល គេរើសដែរនឹងហាស

ក៖ បាទតាបាទ?

ខ៖ បើកឡានក៏គេអោយទៅ ប៉ុន្តែឯងតំរិះវិទ្យាក៏ទៅអត់រួច

ក៖ បាទតាបាទ ចុះសំរាប់តាគិតថា
បើសិនជាចង់អោយតាផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយនឹងតើ តាមានអីចង់ផ្តែផ្តាំដែរតា?

ខ៖ ចង់អោយកូនចៅនឹងចេះឥឡូវនឹងបានកូនមួយនឹងរៀននៅបរិញ្ញាប័ត្រ

ក៖ អូ!!រៀននៅភ្នំពេញហោសតា?

ខ៖ រៀនបានចប់ហើយៗនឹងហាសវាចឹង

ក៖ អូ!!ចប់ហើយហោសតា
ចុះតាចង់ផ្តែផ្តាំថាចង់អោយគាត់រៀនចង់អោយគាត់មានអនាគត់ល្អអីចឹងហាសតា?

ខ៖ បាទនឹងខំចុងផ្តើមកូនមួយនឹង

កៈ ចុះតាបើសិនជាចង់អោយគាត់ជៀសវៀងវិញតើ
តាចង់អោយគាត់ជៀសវៀងអីគេដែរតា?

ខៈ ចេះតែចង់ហើយនឹងប៉ុន្តែខ្លួចវាមិនបានដូចចិត្តនឹង

កៈ ប៉ុន្តែលក្ខណៈថាជាគ្រឿងញៀនអីចឹងហាស?

ខៈ អូ៎!!អានឹងខ្ញុំអត់ចូលចិត្តទេរឿងមួយនឹងហាស

កៈ បាទចង់អោយគាត់ជៀសវៀងណាតា?

ខៈ អោយជៀសវៀងអោយឆ្ងាយអានឹង

កៈ បាទតាបាទនឹងមានអីផ្សេងទៀតទេ?

ខៈ ថ្នាំនឹងអោយតាមិនចូលចិត្តទេ ហើយកូននឹងក៏អត់ចូលចិត្តទៀតនឹង

កៈ បាទតាបាទចឹងហោសតា?

ខៈ បាទអត់ចូលចិត្តទេនឹង

កៈ បាទ!!មានអីផ្សេងទៀតទេ?

ខៈ បាទ!!អត់មានអីផ្សេងទៀតទេនឹង

កៈ
បាទ!!ជាចុងក្រោយខ្ញុំអរគុណច្រើនតាដែរបានអោយខ្ញុំដែរអោយបានសំភាសន៍ដែរទាក់ទ
ងពីប្រវត្តិ របស់តាចឹងណាស់តា
ហើយខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលា
ដើម្បីអោយគាត់បានដឹងនឹងបានស្គាល់ពីប្រវត្តិរបស់តា
ដែរតាបានរៀបរាប់ប្រាប់ខ្ញុំមិញចឹងហាសតា បាទចឹងអរគុណច្រើនតា៕៕៕